**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Oct-2011, 15:17
CMS/CFO: Uch Arun

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣ ខែតុលា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ការគាំទ្រដោយមានលក្ខខណ្ឌរបស់លោក អៀង សារី ចំពោះសេចក្តីជូនដំណឹងអំពីសំណើរបស់សហព្រះរាជអាជ្ញាសុំពិចារណាឡើងវិញនូវលក្ខណ្ឌនៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីអនុលោមតាមវិធាន៨៩ស្ទួនពីរនៃវិធានផ្ទៃក្នុង**

---

<u>ដាក់ដោយ៖</u>

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

<u>ផ្ញើជូន៖</u>

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម យូរ ឧត្តរ៉ា

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង ធូ មណី

ចៅក្រមបំរុង Claudia FENZ

<u>ផ្ញើជូន៖</u>

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តទៅនេះសូមគាំទ្រដោយមានលក្ខខណ្ឌនូវសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ក្នុងសេចក្តីជូនដំណឹងរបស់ខ្លួនអំពីសំណើសុំពិចារណាឡើងវិញនូវលក្ខខណ្ឌនៃ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីស្របតាមវិធាន៨៩ស្ទួនពីរ"[1] "ដែលថាមានមូលដ្ឋានស្របច្បាប់សម្រាប់អង្គជំនុំជម្រះសាលាដំបូង ធ្វើការពិចារណាឡើងវិញនូវលក្ខខណ្ឌនៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងអនុញ្ញាតឲ្យមានសវនាការផ្ទាល់មាត់"។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើរបស់សហព្រះរាជអាជ្ញាសុំពិចារណាឡើងវិញនូវ លក្ខខណ្ឌនៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីស្របតាមវិធាន៨៩ស្ទួនពីរ នោះមេធាវីការពារក្តីសូមស្នើដោយគោរពឲ្យអង្គជំនុំជម្រះសាលាដំបូងផ្តល់ពេលវេលាឲ្យបានគ្រប់គ្រាន់ដល់ភាគីដើម្បីពិនិត្យនិងឆ្លើយតបទៅនឹង"អនុសាសន៍ដែលផ្តោតជាសំខាន់របស់សហព្រះរាជអាជ្ញា"[2] ហើយមេធាវីការពារក្តីក៏ស្នើសុំឲ្យមានសវនាការផ្ទាល់មាត់ជា_សាធារណៈ_ផងដែរ។ គ្មានព័ត៌មានសម្ងាត់ណាមួយនឹងត្រូវលើកយកមកពិភាក្សាដែលអាចរារាំងមិនឲ្យមានសវនាការជាសាធារណៈបានឡើយ។ យោងតាមសារៈសំខាន់នៃបញ្ហាដែលនឹងត្រូវលើកយកមកពិភាក្សា សវនាការជាសាធារណៈប្រកបដោយតម្លាភាពពេញលេញនឹងជួយដល់សាធារណជនកម្ពុជាឲ្យយល់កាន់តែច្បាស់អំពីបញ្ហាជាច្រើនកំពុងស្ថិតក្រោមការពិចារណា ហើយនឹងធ្វើឲ្យមានការពេញចិត្ត និងទំនុកចិត្តឲ្យកាន់តែខ្លាំងថែមទៀត ទៅលើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាពិសេសលើអង្គជំនុំជម្រះសាលាដំបូងតែម្តង។

**អាស្រ័យហេតុនេះ** សម្រាប់មូលហេតុដូចដែលបានលើកឡើងក្នុងញត្តិនេះ មេធាវីការពារក្តីសូមស្នើ ដោយគោរពឲ្យអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈ ប្រសិនបើខ្លួនយល់ព្រមទទួលសំណើរបស់សហព្រះរាជអាជ្ញាសុំការពិចារណាឡើងវិញនូវលក្ខខណ្ឌនៃ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីស្របតាមវិធាន៨៩ស្ទួនពីរ"។

សូមលោក/លោកស្រីចៅក្រមទទួលយកសំណើនេះដោយក្តីគោរព

---

[1] សេចក្តីជូនដំណឹងរបស់ខ្លួនអំពីសំណើសុំពិចារណាឡើងវិញនូវលក្ខខណ្ឌនៃ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីស្របតាមវិធាន៨៩ស្ទួនពីរ", ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១, ឯកសារ E124/1, ត្រង់កថាខណ្ឌទី៤។

[2] ដូចជើងទំព័រខាងលើ, ត្រង់កថាខណ្ឌទី៥។ ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **៣** ខែ **តុលា** ឆ្នាំ **២០១១**

____________________ ____________________

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**